# ការវិវត្តថ្មីៗក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ នៅកម្ពុជា[1]

ផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល បានកំណត់ថា ថ្នាក់ក្រុង ស្រុក និងខណ្ឌ ជាថ្នាក់រដ្ឋបាលដ៏សំខាន់សម្រាប់ជួយលើកកម្ពស់ការផ្ដល់សេវា ការសហការ និងការគាំទ្រដល់ថ្នាក់ឃុំ សង្កាត់។ សេចក្ដីនេះ ជាការរំពឹងទុកមួយយ៉ាងធំចំពោះថ្នាក់រដ្ឋបាល ក្នុងខណៈដែលមុនការបោះឆ្នោតបង្កើតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០០៩ គឺគ្រាន់តែដើរតួនាទីជា ការិយាល័យរដ្ឋបាលមួយរបស់ថ្នាក់រាជធានី ខេត្ត ប៉ុណ្ណោះ។ ដើម្បីសម្រេចបានតាមការរំពឹងទុកនេះ ផអ៣ បានផ្ដោតការយកចិត្តទុកដាក់ទៅលើការរៀបចំបង្កើត និងការអភិវឌ្ឍនូវរដ្ឋបាលប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ ដើម្បីជាជំនួយស្មារតីដល់ការស្វែងយល់ពីកំណែទម្រង់ដ៏សំខាន់នេះ ក្នុងអត្ថបទមានការពិភាក្សាត្រួសៗលើទិដ្ឋភាពគោលនយោបាយសំខាន់ៗដែលបានដាក់ចេញសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងបង្ហាញពីសកម្មភាពដែលក្រុង ស្រុក ខណ្ឌ បានអនុវត្ត បន្ទាប់ពីការបោះឆ្នោតបង្កើតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០០៩។

## ១. គោលនយោបាយសំខាន់ៗសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ

ក្រោមក្របខ័ណ្ឌនៃ ផអ៣ ប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបែងចែកជា ២ប្រភេទគឺ ១) ប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលខេត្ត ដែលមានតួនាទីសំខាន់តំណាងឱ្យរដ្ឋបាលថ្នាក់ជាតិ ក្នុងការសម្របសម្រួល ការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាព និង ២) ប្រព័ន្ធអភិបាលកិច្ច និងរដ្ឋបាលមូលដ្ឋាន មានជាអាទិ៍ រាជធានី ក្រុង ស្រុក ខណ្ឌ ព្រមទាំងឃុំ/សង្កាត់ ដែលមានតួនាទីសំខាន់ក្នុងការបង្កើត ជម្រុញ និងធានាចីរភាពនៃការផ្ដល់សេវា និងអភិវឌ្ឍន៍មូលដ្ឋាន។ រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សាមួយដែលជ្រើសតាំងឡើងតាមការបោះឆ្នោតអសាកល និងគណៈអភិបាលមួយដែលរាជរដ្ឋាភិបាលបានតែងតាំងឡើង[២]។ គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលផង និងក្រុមប្រឹក្សាផង[៣]។ នៅទីជនបទ ក្រុមប្រឹក្សាស្រុកត្រូវមានគណនេយ្យភាពចំពោះថ្នាក់ឃុំ សង្កាត់ ហើយនៅទីប្រជុំជន ក្រុមប្រឹក្សាក្រុងត្រូវមានគណនេយ្យភាពចំពោះសង្កាត់ផង និងត្រូវត្រួតពិនិត្យ និងធ្វើប្រតិភូកម្មការងារនិងធនធានទៅឱ្យសង្កាត់ផង[៤]។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចាំបាច់ត្រូវរៀបចំបង្កើតឱ្យមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួន ៣ គឺគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ និងគណៈកម្មាធិការលទ្ធកម្ម[៥]។ ជាទូទៅគណៈកម្មាធិការទាំងនេះ មានអភិបាលស្រុកជាប្រធាន និងមាននាយករដ្ឋបាល សមាជិកក្រុមប្រឹក្សា មន្ត្រីជំនាញ និងមេឃុំ និងចៅសង្កាត់មួយចំនួនជាសមាជិក។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់យោបល់ដល់ក្រុមប្រឹក្សាអំពីផែនការអភិវឌ្ឍន៍ និងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការសម្របសម្រួលការងារបច្ចេកទេសជាមួយការិយាល័យជំនាញ (RGC 2009b; MoI 2010b) កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់និងអ្នកពាក់ព័ន្ធផ្សេងទៀត និងការចាត់វិធានការផ្សេងៗ ដើម្បីលើកកម្ពស់ការអនុវត្តមុខងារ និងធនធានរបស់ក្រុង ស្រុក ខណ្ឌ។

ក្នុងរយៈពេល១០ឆ្នាំខាងមុខ ថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយរួមសហការជាមួយថ្នាក់ឃុំ សង្កាត់ រំពឹងថានឹងក្លាយទៅជាថ្នាក់រដ្ឋបាលដ៏សកម្ម និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការងារផ្ដល់សេវាសាធារណៈចាំបាច់នានានៅមូលដ្ឋាន។ ដើម្បីសម្រេចបានគោលដៅនេះ ផអ៣ ក្នុងជំហានដំបូង បានផ្ដោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ជួយដឹកនាំ និងដោយមានការចូលរួមពីក្រសួង ស្ថាប័នសំខាន់ៗ ដូចជា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ការអភិវឌ្ឍសមត្ថភាពរបស់ក្រុង ស្រុក ខណ្ឌ ផ្ដោតជាសំខាន់ទាំងលើការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពស្ថាប័នពាក់ព័ន្ធទៅនឹងការរៀបចំ ការបង្កើត និងការពង្រឹងប្រព័ន្ធអភិបាលកិច្ចនិងគណនេយ្យភាព ប្រព័ន្ធផែនការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាល ប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ ដែលទាំងអស់

---

១ អត្ថបទនេះតាក់តែងឡើងដោយលោក ប៉ក់ គឹមជឿន លោកស្រី ធន់ វិមាលា និង លោក គ្រុយ វីរៈ ជាអ្នកស្រាវជ្រាវនៅ CDRI ។

២ មាត្រា ១៤ និង ១៤១ នៃច្បាប់អង្គការ

៣ មាត្រា ១៥៤ នៃច្បាប់អង្គការ

៤ មាត្រា ១០៦-១១៣ នៃច្បាប់អង្គការ

៥ មាត្រា ១៤៤ នៃច្បាប់អង្គការ

នេះ សុទ្ធតែជាសមាសធាតុសំខាន់ៗសម្រាប់ជម្រុញឱ្យថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមត្ថភាពប្រសើរជាងមុន ក្នុងការងារអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន និងផ្ដល់ការគាំទ្រដល់ថ្នាក់ឃុំ/សង្កាត់ ប្រកបដោយប្រសិទ្ធភាព (NCDD 2010d; 2010e)។

ជាទិសដៅផ្នែកគោលនយោបាយ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស ហើយមុខងារទាំងនេះ ត្រូវមានក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគទាំងនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវទទួលបាននូវថវិកាផ្ទេរពីថ្នាក់ជាតិ និងថវិកាប្រមូលបានពីមូលដ្ឋានផ្ទាល់របស់ខ្លួន (NCDD 2010e)។ ប៉ុន្តែ ដូចមានបង្ហាញលម្អិតនៅផ្នែកខាងក្រោយទាំងអស់នេះ កំពុងស្ថិតនៅជាផែនការ ដែលតម្រូវឱ្យមានការគិតគូរ និងខិតខំអនុវត្តជាដំណាក់កាលៗ ទើបអាចសម្រេចបាន។

ថ្នាក់ក្រោមជាតិ ក៏ត្រូវរៀបចំឱ្យមានផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដើម្បីបង្ហាញពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍរយៈពេលវែង រយៈពេលមធ្យម និងរយៈពេលខ្លី និងការកំណត់អាទិភាពសម្រាប់កិច្ចការអភិវឌ្ឍនៅតាមមូលដ្ឋានរបស់ខ្លួន។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក ខណ្ឌ គឺជាលក្ខខណ្ឌចាំបាច់ ដើម្បីទទួលបានធនធាន ពោលគឺ ត្រូវមានផែនការ ទើបមានថវិកា (RGC 2009c; NCDD 2010b)។ វិធានលម្អិតទាក់ទងនឹងការងារថវិកាមានចែងនៅក្នុងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត[៦]។

## ២. សកម្មភាពអភិវឌ្ឍន៍ និងការអភិវឌ្ឍសមត្ថភាព ដែលក្រុង ស្រុក ខណ្ឌបានអនុវត្តកន្លងមក

យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងយោងតាមស្ថានភាពទន់ខ្សោយរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ នៅមុនការបោះឆ្នោតបង្កើតក្រុមប្រឹក្សានាខែឧសភា ២០០៩ នោះ គេឃើញថាការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់នេះ ត្រូវការកិច្ចខិតខំប្រឹងប្រែង និងចំណាយធនធានជាច្រើន។ ទោះជាយ៉ាងនេះក្ដី ក៏មិនគួរភ្លេចដែរថា ក្នុងពេលកន្លងមក ក្រុង ស្រុក ខណ្ឌមួយចំនួន ធ្លាប់បានទទួលការគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ និងគម្រោងកសាងសមត្ថភាពផ្សេងៗ សំដៅពង្រឹងតួនាទីក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមក្នុងការងារអភិវឌ្ឍន៍ និងឆ្លើយតបចំពោះតម្រូវការរបស់ឃុំ/សង្កាត់ និងប្រជាពលរដ្ឋមូលដ្ឋាន។ ខាងក្រោមនេះ គឺជាគម្រោង ៣សំខាន់ៗដែលធ្លាប់បានអនុវត្តលើទិដ្ឋភាពផ្សេងៗគ្នានៅថ្នាក់ក្រុង ស្រុក និងខណ្ឌមួយចំនួន ក្នុងពេលកន្លងមក[៧]។

៦ យោងតាមបទសម្ភាសន៍ថ្ងៃទី១៨ ឧសភា ២០១១ ជាមួយមន្ត្រីជាន់ខ្ពស់ នៃលេខាធិការដ្ឋានរបស់ គជអប។

៧ ក្រៅពីគម្រោងទាំង ៣ នេះ គម្រោងផ្សេងទៀតក៏បានចូលរួមចំណែកដល់ការកសាងសមត្ថភាពរបស់ថ្នាក់ស្រុកដែរ ដូចជា គម្រោង Inter-Communal Cooperation (ICC) និង គម្រោង Cambodian Criminal Justice Assistance Project (CCJAPIII) ជាដើម។

### *កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក*

កម្មវិធីនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយមានការគាំទ្រពី គម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) និង គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ (NRMLP) គាំទ្រដោយរដ្ឋាភិបាលដាណឺម៉ាក ដែលសំដៅចូលរួមចំណែកពង្រឹងរចនាសម្ព័ន្ធ តួនាទី ការអភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់ស្រុក និងជម្រុញឱ្យមានការផ្ទេរជាបណ្ដើរៗទៅឱ្យថ្នាក់ស្រុកនូវ តួនាទី និងសិទ្ធិអំណាចក្នុងការប្រើប្រាស់ និងគ្រប់គ្រងថវិកា (NCDD 2007; NCDD 2009; Mekong Think Tank 2010)។ គិតត្រឹមឆ្នាំ២០១០ កម្មវិធីនេះមាន ១០៦ស្រុកចូលរួម ដោយស្រុកនីមួយៗទទួលបានថវិកាពី ២-៣ម៉ឺនដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់ការរៀបចំ និងអនុវត្តគម្រោង ដែលមានលក្ខណៈអន្តរឃុំនៅក្នុងដែនដីរបស់ខ្លួន។ ចាប់តាំងពីពេលបង្កើតកម្មវិធីនេះមក ជាសរុបមាន ២៣៣៩គម្រោង មានតម្លៃ ១០,៣លានដុល្លារ ដែលត្រូវបានរៀបចំ និងអនុវត្តក្នុងវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ធារាសាស្ត្រ ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ នៅតាមស្រុកគោលដៅទាំងនេះ គេបានរៀបចំឱ្យមានមន្ត្រីបង្គោលសម្រាប់ធ្វើការត្រួតពិនិត្យ តាមដាន វាយតម្លៃ និងប្រមូលទិន្នន័យ ទាក់ទងនឹងការរីកចម្រើន និងបញ្ហាប្រឈមនានាដែលកើតមានឡើង (MoI 2010a)។

តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (គអស) កម្មវិធីនេះ បានបង្រៀនឱ្យថ្នាក់ស្រុកចេះសហការជាមួយឃុំ សង្កាត់ក្នុងការជ្រើសរើស ធ្វើផែនការ និងអនុវត្តគម្រោងអន្តរឃុំ និងបានជម្រុញឱ្យមានការចូលរួមពីមន្ត្រីជំនាញ សំដៅពង្រឹងគណនេយ្យភាព និងការសហការតាមខ្សែទទឹងនៅថ្នាក់ស្រុក។ សរុបមក កម្មវិធីនេះជាបទពិសោធន៍ដ៏ល្អមួយសម្រាប់ឱ្យថ្នាក់ស្រុក ត្រៀមខ្លួនក្នុងការកសាងផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងថវិកាផ្ទាល់ ដែលពួកគេរំពឹងថា នឹងទទួលបានក្នុងពេលឆាប់ៗខាងមុខ[៨]។

### *គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា*
*(ហៅកាត់ថា PILAC)*

PILAC ជាគម្រោងមួយដែលក្រសួងមហាផ្ទៃបានបង្កើតឡើងនៅឆ្នាំ២០០៧ ដោយមានការគាំទ្រពីទីភ្នាក់ងារជំនួយរបស់ប្រទេសជប៉ុន ដើម្បីជួយទ្រទ្រង់ដល់ការកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ស្រុក និងខេត្ត ខាងផ្នែកគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ គម្រោងនេះមានគោលដៅរយៈពេលវែង បង្កើតជាប្រព័ន្ធគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាពមួយនៅថ្នាក់ក្រោមជាតិ ដោយយោងតាមស្មារតីនៃច្បាប់រៀបចំអង្គការ។ ដើម្បីសម្រេចនូវគោលដៅទាំងនេះ គម្រោងបានជួយបណ្ដុះបណ្ដាលគ្រូបង្គោល

៨ យោងតាមបទសម្ភាសន៍នៅថ្ងៃទី១៨ ឧសភា២០១១ ជាមួយមន្ត្រីជាន់ខ្ពស់នៃលេខាធិការដ្ឋានរបស់ គជអប។

ថ្នាក់ជាតិ ដែលបានធ្វើការបណ្តុះបណ្តាល និងចែករំលែកបន្តដល់មន្ត្រីថ្នាក់ក្រោមជាតិ តាមរយៈសិក្ខាសាលាមួយចំនួន។ គម្រោងក៏បានរៀបចំឱ្យមានការសិក្សាផ្សេងៗ សំដៅចងក្រងឯកសារ អំពីស្ថានភាព និងបញ្ហាប្រឈមដែលកើតមានឡើងជាក់ស្តែងទាក់ទងនឹង ការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ (MoI 2008a; MoI 2008b)។ ឯកសារ និងធនធានមនុស្សទាំងនេះ នឹងជួយជាទុនសម្រាប់រដ្ឋបាលថ្នាក់ស្រុក ក្នុងការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន និងការគាំទ្រដល់រដ្ឋបាលឃុំ/សង្កាត់របស់ខ្លួន។

### *គម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ*

គម្រោងនេះ ចាប់ផ្តើមនៅឆ្នាំ២០០៥ នៅក្រុងគោលដៅចំនួន២ គឺក្រុងបាត់ដំបង និងក្រុងសៀមរាប ដោយមានការគាំទ្រពីមូលនិធិខុនរ៉ាតអាដេណូអ៊ែរ និងសហគមន៍អឺរ៉ុប ដើម្បីសាកល្បងធ្វើឱ្យថ្នាក់ក្រុងមានតួនាទីសកម្មជាងមុន ក្នុងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពដល់ប្រជាជន តាមរយៈការបង្កើតការិយាល័យច្រកចេញចូលតែមួយ។ ផ្អែកលើបទពិសោធន៍ និងលទ្ធផលវិជ្ជមាននៃការអនុវត្តគម្រោងសាកល្បងនេះ ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានដល់រាជរដ្ឋាភិបាល តាមរយៈគម្រោងពង្រឹងអភិបាលកិច្ចមូលដ្ឋាន (DFGG) ដើម្បីពង្រីកសកម្មភាពបង្កើតការិយាល័យច្រកចេញចូលតែមួយ នៅតាមក្រុង ស្រុកគោលដៅមួយចំនួនផ្សេងទៀត។ មកទល់បច្ចុប្បន្ន គម្រោងនេះបានពង្រីកដល់ក្រុងចំនួន ៦ គឺមាន ក្រុងតាខ្មៅ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត ក្រុងស្ទឹងសែន ក្រុងសួង ក្រុងក្រចេះ និងដល់ស្រុក ១ គឺ ស្រុកពាមរ (NCDD 2010a)។

តាមរយៈគម្រោងខាងលើ ក្រុង និងស្រុកគោលដៅ បានបង្កើតជាក្របខ័ណ្ឌអនុវត្តគោលនយោបាយមួយ ដែលក្នុងនោះមុខងារផ្តល់សេវាត្រូវបានផ្ទេរពីក្រសួងស្ថាប័នជំនាញចំនួន ៦ វិស័យទៅឱ្យក្រុង និងស្រុកគោលដៅ (RGC 2001)។ គម្រោងក៏បានជួយឲ្យមានការផ្លាស់ប្តូរឥរិយាបថរបស់មន្ត្រីមូលដ្ឋាន ពីអ្នកគ្រប់គ្រង មកជាអ្នកផ្តល់សេវាបម្រើប្រយោជន៍ប្រជាពលរដ្ឋវិញ។ ក្នុងពេលជាមួយគ្នា ប្រជាពលរដ្ឋក៏បានយល់ដឹង និងមានទំនុកចិត្តជាងមុនអំពីបែបបទក្នុងការស្វែងរក និងទទួលបានសេវាពីរដ្ឋអំណាចមូលដ្ឋាន។ លទ្ធផល និងបទពិសោធន៍បានពីគម្រោងអាចក្លាយជាមេរៀនដ៏ប្រសើរសម្រាប់ការរៀបចំគោលនយោបាយផ្ទេរមុខងារ និងវិសហមជ្ឈការតាមវិស័យ (NCDD 2010a; Thon *et al.* 2011)។

## ៣. របកគំហើញស្តីពីសកម្មភាពចាប់តាំងពីមានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ផ្អែកលើលទ្ធផលនៃការចុះសាកសួរក្នុង ៤ស្រុក សកម្មភាពការងារដែលសម្រេចបាន ចាប់តាំងពីមានការបោះឆ្នោតជាអសាកលនៅខែឧសភា ២០០៩ ដើម្បីបង្កើតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានដូចតទៅ៖

### *សកម្មភាពកសាង និងដំណើរការស្ថាប័ន*

តាមការពិនិត្យជាទូទៅ ចាប់តាំងពីការបោះឆ្នោតឆ្នាំ២០០៩ មក ក្រុមប្រឹក្សាស្រុក មានសកម្មភាពតិចតួចណាស់ក្រៅពីការប្រជុំប្រចាំខែ និងការទទួលរបាយការណ៍ពីគណៈអភិបាល។ រឿងនេះ បង្កឡើងមួយផ្នែកដោយសាររដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅមិនទាន់មានផែនការអភិវឌ្ឍន៍ និងថវិកាសមស្របនៅឡើយ។ នៅពេលមានផែនការអភិវឌ្ឍន៍និងថវិកា ក្រុមប្រឹក្សានឹងមានសកម្មភាពជាច្រើនត្រូវបំពេញ។ ទោះជាយ៉ាងនេះក្តី ភាពសកម្មរបស់ក្រុមប្រឹក្សា ក៏អាស្រ័យទៅលើបុគ្គលិកលក្ខណៈរបស់ប្រធាន និងសមាជិកក្រុមប្រឹក្សាផងដែរ។ បច្ចុប្បន្ន ភាគច្រើននៃសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (លើសពី ៦៥% ក្នុងស្រុកទាំង៤ ដែលបានចុះសិក្សា) ស្ថិតក្នុងអាយុកាលចូលនិវត្តន៍។ ភាពចាស់ទុំរបស់ពួកគាត់ ជាគុណប្រយោជន៍ដ៏សំខាន់មួយ ព្រោះគាត់អាចនាំយកបទពិសោធន៍ការងារដ៏សម្បូរបែបរបស់ខ្លួន ទៅបម្រើការងាររបស់ក្រុមប្រឹក្សា ប៉ុន្តែក៏មានសមាជិកក្រុមប្រឹក្សាមួយចំនួនដែលអសកម្ម ឬមិនសូវស្វាហាប់ក្នុងការបំពេញការងារដែរ។

ចំណែកឥទ្ធិពលរបស់ប្រធានក្រុមប្រឹក្សាវិញ មួយផ្នែកអាស្រ័យលើមុខតំណែងពីអតីតកាល និងការជ្រើសតាំងបេក្ខភាពរបស់គាត់ក្នុងការបោះឆ្នោតឆ្នាំ២០០៩។ ក្នុងស្រុកបីដែលបានចុះសាកសួរ ប្រធានក្រុមប្រឹក្សាជាអតីតអភិបាលស្រុក ក្នុងស្រុកនោះផ្ទាល់ ឬមកពីស្រុកផ្សេង ហើយបេក្ខភាពរបស់គាត់ត្រូវបានផ្តួចផ្តើមឡើងដោយគណបក្សថ្នាក់ខេត្ត (សំដៅលើគណបក្សប្រជាជនកម្ពុជា)។ ក្នុងករណីនេះ ប្រធានក្រុមប្រឹក្សាហាក់មានឥទ្ធិពល និងទទួលបានការគោរពច្រើននៅក្នុងរដ្ឋបាលស្រុករបស់ខ្លួន។ នៅស្រុកមួយទៀត ប្រធានក្រុមប្រឹក្សាជាអតីតបុគ្គលិកចាស់ទុំក្នុងស្រុក រីឯបេក្ខភាពរបស់គាត់ត្រូវបានផ្តួចផ្តើមដោយសាខាបក្សស្រុក និងក្រោយមកមានការយល់ព្រមពីគណបក្សថ្នាក់ខេត្ត។ នៅក្នុងករណីនេះ ប្រធានក្រុមប្រឹក្សាហាក់មិនសូវមានឥទ្ធិពលទេ បើប្រៀបធៀបទៅនឹងអភិបាលស្រុក។

ចំពោះគណបក្សនយោបាយ (ជាពិសេសគណបក្សប្រជាជនកម្ពុជា) ភាពចាស់ទុំ និងភាពស្មោះត្រង់ គឺជាលក្ខខណ្ឌចម្បងក្នុងការតែងតាំងបេក្ខភាពសម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយសារហេតុផលពីរ៖ ទី១ ភាពចាស់ទុំ មានន័យថាមានបទពិសោធន៍ការងារច្រើន អាចជួយដល់ការងាររបស់ក្រុមប្រឹក្សា និង ទី២ ការគាំទ្រដល់បេក្ខជនដែលមានភាពចាស់ទុំ និងស្មោះត្រង់ចំពោះបក្ស គឺជាការផ្តល់រង្វាន់មួយ។ ចំពោះចំណុចនេះ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការដឹងគុណយ៉ាងខ្លាំង។ គណបក្សផ្សេងៗទៀត ក៏មានការគិតគូរស្រដៀងគ្នាដែរ។ ក្នុងការសិក្សាបន្តទៀត គេគួរពិនិត្យលើកត្តាគណបក្សនយោបាយនេះក្នុងការកំណត់ពីបេក្ខភាព និងភាពសកម្មរបស់ក្រុមប្រឹក្សា ហើយនិងទំនាក់ទំនងរបស់ក្រុមប្រឹក្សា ជាមួយគណៈអភិបាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

ទោះបីមានក្រុមប្រឹក្សាក៏ដោយ ក៏ក្នុងអំឡុង ២ឆ្នាំកន្លងមកនេះ គណៈអភិបាល និងអភិបាលនៅតែមានសកម្មភាព និងឥទ្ធិពលច្រើនក្នុងការងារជាក់ស្តែង។ នាបច្ចុប្បន្ន គេឃើញមានមន្ត្រីវ័យក្មេងជាច្រើនត្រូវបានតែងតាំងជាអភិបាល ឬជាអភិបាលរង។

ឧទាហរណ៍ ក្នុងខេត្តមួយនោះ អភិបាលស្រុកប្រមាណ ៨០% ត្រូវបានជំនួសដោយមន្ត្រីដែលមានអាយុតិចជាង ៤០ឆ្នាំ និងបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល។ នៅអាណត្តិក្រោយនេះ គេរំពឹងថាអភិបាលស្រុកដែលបានបម្រើការ ១០-១៥ឆ្នាំមកហើយនោះ នឹងដល់អាយុចូលនិវត្តន៍ ហើយត្រូវជំនួសដោយមន្ត្រីជំនាន់ក្រោយ[៩]។

ក្រុមប្រឹក្សាស្រុកបានបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ (MoI 2009) និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស (RGC 2009b) រួចហើយ ប៉ុន្តែមិនទាន់បានបង្កើតគណៈកម្មាធិការលទ្ធកម្មទេ ដោយសារមិនទាន់ទទួលបានការណែនាំលម្អិតស្តីពីការរៀបចំបង្កើតគណៈកម្មាធិការនេះ។ ការប្រកាន់និន្នាការគណបក្សនយោបាយ មិនត្រូវបានពិនិត្យឃើញទេក្នុងការរៀបចំគណៈកម្មាធិការពិគ្រោះយោបល់នានា ប៉ុន្តែចំណុចនេះគួរធ្វើការសិក្សាបន្ថែមក្នុងក្រុង ស្រុក ផ្សេងៗទៀត។

ចំណែកខាងរដ្ឋបាលស្រុកវិញ គេក៏ឃើញមានការផ្លាស់ប្តូរមន្ត្រីពីមន្ទីរស្រុកទៅជានាយករដ្ឋបាលស្រុកចំនួនមួយរូប និងនាយករងចំនួនពីររូប។ ក្នុងនោះក៏មានការបង្កើតនូវការិយាល័យចំណុះចំនួន៣ គឺមាន ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យផែនការនិងគាំទ្រឃុំ/សង្កាត់ និងការិយាល័យអន្តរវិស័យ។ ក្រោមក្របខ័ណ្ឌនៃ ជអ៣ មានការជ្រើសរើស និងតែងតាំងទីប្រឹក្សាថ្នាក់ស្រុក ដើម្បីជួយគាំទ្រលើការអភិវឌ្ឍសមត្ថភាព និងសម្របសម្រួលសកម្មភាពអភិវឌ្ឍន៍នានា ហើយក៏ប្រហែលជាអាចមានការគិតគូររៀបចំឱ្យមាន មន្ត្រីជំនួយផ្នែកបច្ចេកទេសនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ផងដែរ[១០]។

បញ្ហាប្រឈមសម្រាប់រដ្ឋបាលស្រុកនាបច្ចុប្បន្ន គឺកង្វះសមត្ថភាពរបស់បុគ្គលិក និងកង្វះការសហការពីការិយាល័យជំនាញ។ ឧទាហរណ៍ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ត្រូវពឹងលើជំនួយពីមន្ត្រីសម្របសម្រួលថ្នាក់ស្រុក រួមជាមួយនឹងសមាជិកក្រុមប្រឹក្សាមួយចំនួនដែលមានបទពិសោធន៍លើការងារនេះ ដើម្បីជួយបុគ្គលិករបស់ខ្លួន ដែលមិនសូវមានបទពិសោធន៍លើការងាររៀបចំផែនការ។ ចំណែកឯមន្ត្រីនៃការិយាល័យជំនាញមួយចំនួនងណោះវិញ គឺនៅតែបំពេញការងារតាមការបង្គាប់នៃខ្សែបណ្តោយ។

ភាពអសកម្ម និងកង្វះការសហការរបស់ការិយាល័យជំនាញបណ្តាលមកពីបៀវត្សរ៍តិចតួច និងបញ្ហាពុំទាន់មានការផ្ទេរមុខងារតាមវិស័យ និងធនធានតាមវិស័យឱ្យបានច្បាស់លាស់។ សំខាន់ជាងនេះទៀត ការចូលរួមរបស់ការិយាល័យខ្សែបណ្តោយមិនមែនទាមទារត្រឹមតែការផ្លាស់ប្តូររបៀបរបបធ្វើការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានគោលនយោបាយថ្នាក់ជាតិមួយច្បាស់លាស់សម្រាប់ការផ្ទេរមុខងារ និងធនធាន។

## *ការកសាងផែនការអភិវឌ្ឍន៍ និងរៀបចំថវិកា*

ក្នុងរយៈពេល២ឆ្នាំកន្លងមក រដ្ឋាភិបាលបានរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសនានាទាក់ទងនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលមួយចំនួន ទាក់ទងនឹងការងារនេះ (NCDD 2011)។ គិតត្រឹមចុងខែឧសភា ២០១១ ស្រុកដែលយើងចុះទៅសាកសួរ ទើបតែបានបញ្ចប់ការងារកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការអភិវឌ្ឍនៅតាមកន្លែងនីមួយៗ។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនេះ នឹងត្រូវដាក់ឲ្យអនុវត្តយ៉ាងពេញលេញនៅពេលដែលស្រុកទទួលបាននូវមូលនិធិក្រុង ស្រុក ដែលគេរំពឹងថានឹងមានបង្កើតឡើងនាពេលឆាប់ៗ[១១]។

ជាសង្ខេប ផែនការអភិវឌ្ឍន៍៥ឆ្នាំ ផ្តល់ជាទិសដៅសម្រាប់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្វើការអភិវឌ្ឍក្នុងរយៈពេល៥ឆ្នាំ រីឯកម្មវិធីវិនិយោគ៣ឆ្នាំរំកិល បង្ហាញពីសកម្មភាព និងគម្រោងជាក់ស្តែងដែលត្រូវធ្វើជារៀងរាល់ឆ្នាំ (RGC 2009c)។ ក្នុងការកសាងផែនការទាំងនេះ ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារមួយដែលរួមមានអភិបាលស្រុក ក្រុង អភិបាលរង នាយករដ្ឋបាល និងប្រធានការិយាល័យផែនការនិងគាំទ្រឃុំ/សង្កាត់ ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ប្រធានការិយាល័យជំនាញពាក់ព័ន្ធ និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀត។ នៅពេលកសាងរួច ក្រុមការងារត្រូវដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ជូនទៅគណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីពិនិត្យ និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សាធ្វើការពិភាក្សា និងអនុម័ត។ ផែនការអនុម័តដោយក្រុមប្រឹក្សា ត្រូវផ្ញើទៅជូនអភិបាលខេត្តដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការដែលអនុម័តរួចរាល់ហើយ គឺក្លាយជាឯកសារផ្លូវការ ហើយអាចដាក់ឱ្យសាធារណជនត្រួតពិនិត្យបាន (MoI 2010c)។

ផែនការអភិវឌ្ឍន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ ពឹងលើទិន្នន័យបានមកពី ១) ឃុំ/សង្កាត់ ២) ការិយាល័យជំនាញ ៣) អង្គការមិនមែនរដ្ឋាភិបាល និង ៤) វិស័យឯកជន។ ក្រុង ស្រុក ខណ្ឌ ត្រូវសង្ខេប ធ្វើសំយោគ និងកំណត់អាទិភាពនៃសកម្មភាពដែលបានលើកឡើងទាំងនេះ (NCDD 2010c)។ មន្ត្រីស្រុកបានលើកឡើងថា ពួកគាត់មានការងាយស្រួលក្នុងការប្រមូល និងធ្វើសំយោគលើសំណើរបស់ឃុំ/សង្កាត់ ព្រោះមានបទពិសោធន៍ធ្វើការងារជាច្រើនជាមួយឃុំ/សង្កាត់ ក្នុងពេលកន្លងមក។ ប៉ុន្តែការិយាល័យជំនាញ កំពុងជួបបញ្ហាប្រឈមក្នុងដំណើរការនេះ ព្រោះពុំសូវមានបទពិសោធន៍ក្នុងការកសាងផែនការ ដែលត្រូវយកមកបូកសរុបនៅថ្នាក់ស្រុក ដោយធ្លាប់តែកសាងផែនការក្នុងវិស័យរបស់ខ្លួនផ្ទាល់។

៩ កិច្ចសម្ភាសន៍ជាមួយអភិបាលស្រុក (ថ្ងៃទី៣ ឧសភា ២០១១)

១០ ibid

១១ នេះជាការរំពឹងទុករបស់អភិបាលស្រុក និងសមាជិកក្រុមប្រឹក្សាដែលបានឆ្លើយសម្ភាសន៍។ បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ (ថ្ងៃទី១៨ មិថុនា ២០១១) បានបង្ហាញពីភាពមិនច្បាស់លាស់នៃកាលវេលាដែលមូលនិធិស្រុក ក្រុង ត្រូវបង្កើតឡើង និងផ្ទេរ។

មន្ត្រីស្រុក ដែលក្រុមស្រាវជ្រាវធ្លាប់ជួបសំណេះសំណាល បានប្រាប់ថា បទពិសោធន៍ជាមួយនឹងកម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក បានជួយឱ្យពួកគេងាយស្រួលកំណត់អាទិភាពរបស់ឃុំ/សង្កាត់ (ឧទាហរណ៍ គម្រោងអន្តរឃុំ) ហើយបំប្លែងតម្រូវការទាំងនោះ ឱ្យមកជាអាទិភាពរបស់ស្រុក។ ទិន្នន័យស្ដីពីស្ថានភាពអភិវឌ្ឍន៍មូលដ្ឋាន ដែលត្រូវបានចងក្រងឡើងសម្រាប់ការងាររបស់ឃុំ កន្លងមក មានប្រយោជន៍ខ្លាំងណាស់សម្រាប់ការវិភាគពីស្ថានភាពអភិវឌ្ឍន៍ក្នុងស្រុក។ ប៉ុន្តែពួកគេជួបការលំបាកក្នុងការទទួលបានទិន្នន័យពីអង្គការមិនមែនរដ្ឋាភិបាល និងសហគ្រាសឯកជន ដែលជាអ្នកផ្ដល់សេវាយ៉ាងសំខាន់នៅតាមមូលដ្ឋានស្រុកនីមួយៗ។ គេសង្ឃឹមថា ការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល នឹងមានការចូលរួមកាន់តែច្រើននៅឆ្នាំក្រោយពីសំណាក់តួអង្គមិនមែនរដ្ឋាភិបាលទាំងនេះ ។

## ៤. សេចក្ដីសន្និដ្ឋាន

តាមការពិនិត្យឃើញជាទូទៅ កំណែទម្រង់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ នាបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលដំបូង និងមានសកម្មភាពតិចតួចនៅឡើយ បើប្រៀបធៀបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលចង់ឱ្យថ្នាក់នេះមានសកម្មភាពខ្លាំងក្លាក្នុងការងារផ្ដល់សេវា និងអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ប៉ុន្តែយើងមិនគួរភ្លេចទេថា លទ្ធផលសម្រេចបាន គឺជាផ្លែផ្កាគួរឱ្យមានមោទនភាព បន្ទាប់ពីមានការខិតខំប្រឹងប្រែង ការពិភាក្សាពិគ្រោះយោបល់ និងការចរចាជាច្រើនឆ្នាំ ទាំងនៅកម្រិតបច្ចេកទេស និងកម្រិតនយោបាយ។ ជាការពិតណាស់ ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវការពេលវេលាច្រើន ប៉ុន្តែក៏ពុំមែនចាប់ផ្ដើមពីចំណុចសូន្យនោះដែរ ព្រោះកន្លងមកពួកគេធ្លាប់មានបទពិសោធន៍ និងធ្លាប់ទទួលបានការកសាងសមត្ថភាពពីគម្រោងសាកល្បងមួយចំនួនហើយ។ តាមរយៈគម្រោងទាំងនោះ ថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្លាប់បានរៀនសូត្រ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ឃុំ សង្កាត់ និងបានរៀនអនុវត្ត និងគ្រប់គ្រងការងារអភិវឌ្ឍន៍ដែលមានការចូលរួម និងការអនុលោមតាមវិធានដ៏ច្បាស់លាស់។ ម្យ៉ាងទៀត ទោះបីជាការងារបច្ចេកទេស និងការងារគ្រប់គ្រង មានសារៈសំខាន់សម្រាប់ជម្រុញអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍនៅថ្នាក់មូលដ្ឋានយ៉ាងណាក៏ដោយ ក៏គេមិនត្រូវភ្លេចពីសារៈសំខាន់នៃកត្តានយោបាយ គណបក្សនយោបាយ និងការចូលរួមពីដៃគូមិនមែនរដ្ឋាភិបាល នៅក្នុងការងារនេះដែរ។

## ឯកសារយោង


Mekong Think Tank (2010), *Study of NCDD: Systems suitability for NRM in D&D implementation* (Phnom Penh: Mekong Think Tank)

Ministry of Interior (2009), *Prakas 4275 BRK on the Establishment and the Functioning of the Women's and Children's Consultative Committees at Capital, Provincial, Municipal, District and Khan Councils* (Phnom Penh: MoI)

Ministry of Interior (2010a), *National District Initiatives Project Report 2006-2010* (Phnom Penh: MoI)

Ministry of Interior (2010b), *Prakas no. 2417 on the preparation of the development plan and three year rolling plan of the capital, proivnces, municipalities, districts and khans* (Phnom Penh: MoI)

Ministry of Interior (2008a), *Situational Analysis 1 of Provincial/Municipal and Districts/Khans Administrations in Cambodia* (Phnom Penh: MoI)

Ministry of Interior (2008b), *Situational Analysis 2 of Provincial/Municipal and Districts/Khans Administrations in Cambodia* (Phnom Penh: MoI)

National Committee for Sub-national Democratic Development (2007), *Guideline for the Implementation of District Initiatives (DI)* (Phnom Penh: NCDD)

National Committee for Democratic Development (2010a), *Annual Progress Report for One Window Service Office and District Ombudsman (OWSO-DO)* (Phnom Penh: NCDD)

National Committee for Democratic Development (2010b), *National Capacity Development Framework for the 3-Year Implementation Plan (IP3)* (Phnom Penh: NCDD)

National Committee for Democratic Development (2010c), *Technical guideline on the preparation of the development plan and investment plan for municapalities, districts and khans* (Phnom Penh: NCDD)

National Committee for Democratic Development (2010d), *Outline of the First 3-Years Implementation Plan of the NP-SNDD* (Phnom Penh: NCDD)

National Committee for Democratic Development (2010e), *Implementation Plan First Three Years (2011-2013)* (Phnom Penh: NCDD)

National Committee for Democratic Development (2011), *A compilation of the key regulations and guidelines on the preparation of the development and investment program for the capital, provinces, municipalities, districts, and khan* (Phnom Penh: NCDD)

Royal Government of Cambodia (1994), *Law on General Status of Civil Servants of Cambodia* (Phnom Penh: RGC)

Royal Government of Cambodia (2001), *Council for Administrative Reform: Governance Action Plan* (Phnom Penh: RGC)

Royal Government of Cambodia (2008), *Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans* (Phnom Penh: RGC)

Royal Government of Cambodia (2009a), *Sub-decree 216 on Roles, Duties, and Working Relationship of the Provincial Council and Board of Governors, Municipal*

*Council and Board of Governors and District Council and Board of Governors* ( Phnom Penh: RGC )

Royal Government of Cambodia ( 2009b ), *Sub-decree no. 218 ank.bk on the Establishment, Organization and Functioning of the Technical Facilitation Committee of the Provincial, Municipal and District Council* ( Phnom Penh: RGC )

Royal Government of Cambodia ( 2009c ), *Sub-decree no. 219 ankr.bk on the development and 3 year rolling investment plan for the capital, provnices, municipalities, districts, and khans* ( Phnom Penh: RGC )

Thon, Vimealea, Heng Seiha, Kruy Virak & Ly Tem ( 2011 ), "Assessment of One Window Service Office and District Ombudsman Pilot Project", *Annual Development Review 2010-11* ( Phnom Penh: CDRI )

## *តពីទំព័រ ៥* ជម្រុញកំណើនសេដ្ឋកិច្ចខ្ពស់ ...

ក្រាហ្វិក ៣. ការប៉ាន់ស្មានពីការពង្រីកបណ្ដាញចែកចាយថាមពល




ប្រភព៖ បទបង្ហាញក្នុងសន្និសីទចក្ខុវិស័យឆ្នាំ២០១១

### ការប្រមើលឃើញ និងអាទិភាព

សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញល្អគួរឲ្យកត់សម្គាល់ពីការប៉ះទង្គិចដោយវិបត្តិសេដ្ឋកិច្ចសាកល។ កំណើនសេដ្ឋកិច្ច មានសន្ទុះខ្លាំង និងរំពឹងថានៅថេរក្នុងរយៈពេលពីរបីឆ្នាំខាងមុខ។ ប៉ុន្ដែឥឡូវនេះ ត្រូវត្រៀមរៀបចំខ្លួនជាបន្ទាន់សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីកសាងសេដ្ឋកិច្ចលើគ្រឹះដ៏រឹងមាំ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងរៀបចំប្រទេសដើម្បីទទួលបានកំណើនខ្ពស់ ប្រកបដោយចីរភាព និងសមធម៌។ រាជរដ្ឋាភិបាលមានគោលគំនិតច្បាស់លាស់ពីបញ្ហាត្រូវប្រឈមមុខ និងមានឆន្ទៈចង់ដោះស្រាយ ចង់បំបាត់ឧបសគ្គ តាមការអនុវត្តគោលនយោបាយផ្ដោតចំគោលដៅ និងមានការសម្របសម្រួល។ កង្វះសមត្ថភាពស្ថាប័ន បានរារាំងគោលនយោបាយមិនឲ្យសម្រេចបានតាមគោលដៅកំណត់ទុក ហើយវាជាឧបសគ្គដែលគេបានគូសបញ្ជាក់ជាច្រើនលើកក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១។ ការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ក្នុងការរៀបចំច្បាប់ បទបញ្ញត្តិ និងបង្កើតក្របខ័ណ្ឌគោលនយោបាយប្រកបដោយ គំនិតបែបថ្មី បានបើកចំហប្រទេសកម្ពុជា និងសម្រេចបានកំណើន និងវិបុលភាពកម្រិតខ្ពស់មិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ប៉ុន្ដែ ដើម្បីឲ្យកំណើននេះអាចបន្តទៅមុខ និងមានតម្លាភាព ស្ថាប័ននានាដែលបានកសាងឡើងលើគោលការណ៍អភិបាលកិច្ចល្អ ត្រូវអនុវត្តតាមគោលនយោបាយបានរៀបចំឡើង ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចចម្រុះ ប្រកបដោយចីរភាព និងសមភាព។ ទោះបីតាមការបង្កើតបទបញ្ញត្តិគ្រប់គ្រងទីផ្សារឥណទាន ឬតាមការអនុវត្តកម្មវិធី TVET យ៉ាងសក្ដិសិទ្ធិក្ដី សមត្ថភាពស្ថាប័នសំខាន់ណាស់ក្នុងការធានាឲ្យមានការអនុវត្ត និងពង្រឹង គោលនយោបាយនានារបស់រដ្ឋាភិបាល និងការតាមដានលទ្ធផល។

ការពង្រឹងសមត្ថភាពស្ថាប័នរបស់កម្ពុជា ត្រូវមានការកសាងសមត្ថភាពក្នុងរយៈពេលវែង និងការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងទិសដៅដែលបានដាក់ចេញ។ ប៉ុន្ដែតាមធម្មតា ការងារនេះតែងជួបការលំបាក ដោយសារភាពមិនស៊ីគ្នារវាងការរំពឹងទុករបស់ដៃគូអភិវឌ្ឍន៍ និងភាពជាក់ស្ដែងនៃសមត្ថភាពស្ថាប័ន។ ជាទូទៅ ដៃគូអភិវឌ្ឍន៍តែងរំពឹងចង់បានលទ្ធផលឆាប់រហ័ស ប៉ុន្ដែភាពទន់ខ្សោយជាប្រព័ន្ធជាក់ស្ដែងក្នុងស្ថាប័នកម្ពុជា ត្រូវការពេលវេលាយូរ ដើម្បីដោះស្រាយ។ សមត្ថភាពស្ថាប័ន មិនមែនត្រឹមតែជាបញ្ហាសេដ្ឋកិច្ច-សង្គមកិច្ចនោះទេ ប៉ុន្ដែ មានទាក់ទងនឹងទិដ្ឋភាពនយោបាយ ព្រមទាំងវប្បធម៌សំខាន់ៗទៀតផង ហើយបញ្ហាទាំងនេះមិនអាចដោះស្រាយបានភ្លាមៗនោះទេ។ ដើម្បីឲ្យមានប្រសិទ្ធភាពល្អ ការរំពឹងទុក និងភាពជាក់ស្ដែង ត្រូវតែសម្របសម្រួលឲ្យស៊ីគ្នា តាមរយៈអន្តរាគមន៍ខាងគោលនយោបាយដ៏សមស្រប។ រដ្ឋាភិបាលយល់ឃើញដោយប្រាកដនិយមថា ការកសាងសមត្ថភាពស្ថាប័ន ត្រូវប្រើពេលពី ៥-១០ឆ្នាំ ដើម្បីឈានដល់ស្តង់ដារស្ថាប័នសាកល ហើយដៃគូអភិវឌ្ឍន៍នានា គួរតែអនុវត្តការងារ ព្រមទាំងរៀបចំ និងសម្របសម្រួលគោលនយោបាយឆ្លើយតបឲ្យស៊ីគ្នានឹងក្របខ័ណ្ឌពេលវេលានេះ។

### ឯកសារយោង

បទបង្ហាញនានាក្នុងសន្និសីទចក្ខុវិស័យ អាចរកបាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI: www.cdri.org.kh។